ញុំ ដែលបាននាំយកគំនិតខ្ញុំ គិតអំពីបន្ទប់ឧស្ម័នពុលនៅក្នុង អូសស្វីស ដែលមានមនុស្សចំនួន ៦០០នាក់បានស្លាប់ក្នុងពេលតែ មួយ។ ខ្ញុំគិតថា យើងមិនអាចចាប់ផ្ដើមស្រមៃថាតើហេតុការណ៍នេះគួរឲ្យភ័យខ្លាចយ៉ាងណានោះ ទេ្បីយ។ ប៉ុន្តែវាពិតជាស្ថាននរកមែន?

យើងអាចទៅទស្សនានៅក្នុងបន្ទប់ឧស្ម័នពុល ពីព្រោះតែយប់ដ៏អាក្រក់ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៩៤៥។ ឥឡូវនេះអ្នកអាចចូលទៅទស្សនានៅក្នុងជំរុំបាន។ គ្មានមនុស្សណាម្នាក់ត្រូវបានទទួលការធ្វើទារុញកម្ម ឬដាក់គុកនៅទីនោះទៀតទេ។ បន្ទប់ឧស្ម័នពុលនៅក្នុងអូសស្វីសត្រូវបានបញ្ចាប់។ ប៉ុន្តែ ស្ថាននរកនៅក្នុងព្រះគម្ពីរគឺអស់កល្បជានិច្ច។

នៅក្នុងផ្លូវចូលទៅក្នុងសារៈមន្ទីរនៅក្នុងជំរុំ ខ្ញុំបានសំគាល់ឃើញរូបភាពនៃរូបកាយរបស់ព្រះយេស៊ូវ គ្រីស្ទជាប់នៅលើឈើឆ្កាងព្យួរនៅលើជញ្ជាំង។ មានអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសជាច្រើនបាន ដាក់ក្ដីសង្ឃឹមរបស់ខ្លួនទៅលើព្រះយេស៊ូវ ដែលទ្រង់បានឆ្កាងតាមរយៈការគូសរូបនេះនៅលើជញ្ជាំង ជាមួយនឹងដែកគោល។ មនុស្សម្នាក់នេះបានស្លាប់នៅក្នុងបន្ទប់ឧស្ម័នពុលផងដែរ។ ប៉ុន្តែគាត់បានដឹងអំពីព្រះសង្គ្រោះគឺព្រះយេស៊ូវ។ គាត់បានស្លាប់នៅក្នុងកន្លែងដែលគួរឲ្យភ័យខ្លាច ប៉ុន្តែគាត់ត្រូវបាន ស្វាគមន៍ ដើម្បីនឹងចូលទៅក្នុងនគរស្ថានសួគ៌។ តាមពិតគ្មានផ្លូវណាដែលអាចគេចផុតពីស្ថាននរក ដែលព្រះយេស៊ូវបានពិពណ៌នានៅក្នុងព្រះគម្ពីរសញ្ញាថ្មីនោះទេ្បីយ (ឧ. ម៉ាថាយ ៧៖១៣, ម៉ាថាយ ៥៖២៩-៣០, ម៉ាថាយ ១៨៖៨) ។ អ្នកមិនអាចធ្វើទស្សនៈកិច្ចទៅស្ថាននរកបានទេ្បីយ វាជាកន្លែងមួយ ដែលពេញដោយភាពភ័យខ្លាច និងការឈឺចាប់គ្មានទីបញ្ចាប់។

នគរស្ថានសួគ៌គឺជាកន្លែងអស់កល្បផងដែរ ហើយជាកន្លែងដែលព្រះជាម្ចាស់ចង់យកយើងទៅទីនោះ ។ ដូច្នេះ ចូរអនុញ្ញាត្តិឲ្យខ្លួនរបស់អ្នកបានទទួលការអញ្ជើញទៅស្ថានសួគ៌។ ចូរអំពាវនាវដល់ព្រះនាម របស់ព្រះអម្ចាស់ និងចូរកក់កន្លែងនៅស្ថានសួគ៌!។ បន្ទាប់ពីការនិយាយរបស់ខ្ញុំភ្លាម មានស្ត្រីម្នាក់បាន មកសួរខ្ញុំ។ នាងមានការអន់ចិត្តណាស់ ហើយសួរខ្ញុំថា៖ "តើអាចឲ្យមនុស្សម្នាក់កក់នគរស្ថានសួគ៌ យ៉ាងដូចម្ដេច? ពីព្រោះ ពេលស្លាប់ទៅវាហាក់បីដូចជាការធ្វើដំណើរកំសាន្ត!" ខ្ញុំយល់ស្របជាមួយនឹង នាង "ប្រសិនបើអ្នកមិនកក់កន្លែង នោះអ្នកមិនអាចទៅកន្លែងដែលខ្លួនចង់ទៅនោះទេ។ ប្រសិនបើ អ្នកចង់ធ្វើដំណើរទៅក្រុងហាវ៉ៃ អ្នកត្រូវការសំបុត្រមួយ!"។ ប៉ុន្តែនាងបានឆ្លើយតបថា៖ "ប៉ុន្តែអ្នក ត្រូវតែចំណាយលុយដើម្បីទិញសំបុត្រ"។ ខ្ញុំបានឆ្លើយតបថា៖ "ត្រឹមត្រូវហើយ! តែសំបុត្រទៅស្ថាន សួគ៌ក៏យើងត្រូវតែចំណាយលុយដើម្បីទិញដែរ ប៉ុន្តែវាមានតម្លៃថ្លៃពេក គ្មាននរណាម្នាក់អាចនឹងមានលុយទិញបានទេ្បីយ។ អំពើបាបរបស់យើងបានរារាំងយើងមិនឲ្យចូលទៅក្នុងនគរស្ថានសួគ៌។ ព្រះជា ម្ចាស់មិនអាចទ្រាំទ្រជាមួយនឹងអំពើបាបនៅស្ថានសួគ៌នោះទេ្បីយ។ ប្រសិនបើអ្នកចង់រស់នៅជាមួយ នឹងព្រះជាម្ចាស់អស់កល្បជានិច្ចនៅស្ថានសួគ៌នោះ អ្នកត្រូវតែទទួលសេចក្ដីសង្គ្រោះចេញពីអំពើបាប។កិច្ចការនេះគឺអាចធ្វើបានតាមរយៈមនុស្សម្នាក់ដែលគ្មានអំពើបាប ហើយមនុស្សម្នាក់នោះគឺជាព្រះ យេស៊ូវគ្រីស្ទ។ ទ្រង់គឺជាព្រះអម្ចាស់តែមួយដែលអាចសងថ្លៃសម្រាប់អ្នក ដើម្បីឲ្យអ្នកអាចទៅស្ថាន សួគ៌បាន ។ ទ្រង់បានសងថ្លៃដោយព្រះលោហិតរបស់ទ្រង់នៅលើឈើឆ្កាង"។



© wwing - istockphoto.com

ដូច្នេះ តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីឡើងទៅស្ថានសួគ៌? ព្រះជាម្ចាស់បានអញ្ជើញយើងទាំងអស់គ្នា។ គឺមានបទគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរ ដែលបានជំរុញពួកយើងដើម្បីឲ្យទទួលការអញ្ជើញរបស់ព្រះ ជាម្ចាស់។

- *"ចូរខំប្រឹងយ៉ាងអស់ពីចិត្ត អោយបានចូលទៅតាមទ្វារចង្អៀតវ ដ្បិតខ្ញុំប្រាប់អ្នករាល់ គ្នាថា នឹងមានមនុស្សជាច្រើនខំប្រឹងរកចូលដែរ តែចូល មិនបានទេ* (លូកា ១៣៖២៤)។
- *តាំងពីគ្រាមក ព្រះយេស៊ូវក៏ចាប់ប្រកាស ដោយបន្ទូលថា ចូរប្រែចិត្តឡើង ដ្បិតនគរ ស្ថានសួគ៌ ជិតដល់ហើយ* (ម៉ាថាយ ៤៖១៧)។
- *ចូរឲ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វាដែលនាំទៅឯសេចក្ដីហិនវិនាស នោះធំហើយ ទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វានោះ ១៤តែងទ្វាដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ* (ម៉ាថាយ ៧៖១៣ -១៤)។
- *ចូរប្រឹងតស៊ូ ដោយការតយ៉ាងល្អនៃសេចក្ដីជំនឿ ចូរតោងចាប់ជីវិតអស់កល្បជានិច្ចឱ្យខ្ជាប់ ដែលព្រះបានហៅអ្នកមកទទួល* (១ ធីម៉ូថេ ៦៖១២)។
- *ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារ លោកផង ?* (កិច្ចការ ១៦៖៣១)។

បទគម្ពីរទាំងនេះជាបទគម្ពីរមួយដែលជំរុញឲ្យយើងទទួលការអញ្ចើញ។ អ្នកអាចមានអារម្មណ៍អំពី ភាពបន្ទាន់ និងសេចក្ដីស្មោះត្រង់ដែលស្ថិតនៅក្នុងបទគម្ពីរទាំងនេះ។ កិច្ចការមួយដែលសមហេតុផល សម្រាប់អ្នកគឺទទួលការអញ្ជើញ តាមរយៈសេចក្ដីអធិស្ឋាន ដូចជាខាងក្រោមនេះ៖

"ព្រះអម្ចាស់ ព្រះយេស៊ូវ ទូលបង្គំបានអានអត្ថបទនេះ ហើយបានដឹងថាទូលបង្គំអាចទៅនគរស្ថាន សួគ៌បាន តាមរយៈតែទ្រង់មួយ។ ទូលបង្គំចង់នៅជាមួយនឹងទ្រង់នៅស្ថានសួគ៌នៅថ្ងៃណាមួយ។ សូមទ្រង់បានសង្គ្រោះទូលបង្គំចេញពីស្ថាននរក ដែលជាកន្លែងដែលទូលបង្គំសមនឹងទៅដោយ ព្រោះតែបាបរបស់ទូលបង្គំទាំងអស់។ ពីព្រោះតែទ្រង់បានស្រលាញ់ទូលបង្គំយ៉ាងខ្លាំង ទ្រង់បាន សុគត សម្រាប់ទូលបង្គំនៅលើឈើឆ្កាង ហើយនឹងយកទោសរបស់ទូលបង្គំដាក់លើរូបអង្គទ្រង់"។ ទ្រង់អាចមើលឃើញអំពើបាបរបស់ទូលបង្គំ ចាប់តាំងពីទូលបង្គំនៅពីក្មេងរហូតដល់ពេលនេះ។ ទ្រង់បានជ្រាបគ្រប់ទាំងសេចក្ដីខុសឆ្គងដែលទូលបង្គំបានប្រព្រឹត្ត កិច្ចការដែលចូលក្នុងចិត្តរបស់ទូល បង្គំឥឡូវនេះ និងកិច្ចការដែលទូលបង្គំមិនបានចាប់អារម្មណ៍ ឬមិនបានដឹងខ្លួន។ ទ្រង់បានដឹងអំពីចិត្ត របស់ទូលបង្គំ។ នៅចំពោះព្រះនេត្រទ្រង់ទូលបង្គំគឺជាសៀវភៅមួយក្បាលដែលបានបើក។ ក្នុងនាម របស់ទូលបង្គំគឺទូលបង្គំមិនអាចទៅនគរស្ថានសួគ៌ជាមួយនឹងទ្រង់នោះទេ្បីយ។ ទូលបង្គំពិតជាសោក ស្ដាយណាស់ ហើយសូមទ្រង់បានលើកលែងទោសបាបដល់ទូលបង្គំផង។ សូមទ្រង់យាងមកក្នុង ជីវិតរបស់ទូលបង្គំ ហើយនឹងកែប្រែជីវិតរបស់ទូលបង្គំឲ្យបានក្លាយទៅជាថ្មី។ សូមទ្រង់បានជួយដល់ទូលបង្គំដើម្បីលះបង់ចោលនូវអ្វីដែលមិនត្រឹមត្រូវក្នុងព្រះនេត្ររបស់ទ្រង់។ សូមទ្រង់បានជួយដល់ ទូលបង្គំដើម្បីបង្កើតនូវទម្លាប់មួយដែលល្អក្នុងជីវិត។ សូមឲ្យទ្រង់បានជួយដល់ទូលបង្គំ ដើម្បីយល់ នូវព្រះបន្ទូលរបស់ទ្រង់គឺព្រះគម្ពីរ។ សូម្បីជួយដល់ទូលបង្គំ នៅពេលដែលទ្រង់មានបន្ទូលមកកាន់ទូលបង្គំ ហើយនឹងប្រទាននូវចិត្តនៃការស្ដាប់បង្គាប់ ដើម្បីនឹងឲ្យទូលបង្គំអាចបំពេញតាម ព្រះហឫទ័យរបស់ទ្រង់។ សូមឲ្យទ្រង់បានក្លាយទៅជាព្រះជាម្ចាស់នៃជីវិតទូលបង្គំចាប់ពីពេលនេះទៅ។ ទូលបង្គំចង់ដើរតាមទ្រង់។ សូមបង្ហាញដល់ទូលបង្គំនូវផ្លូវដែលត្រឹមត្រូវក្នុងគ្រប់ទាំងទស្សនៈនៅក្នុង ជីវិតរបស់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណដល់ទ្រង់ ដែលទ្រង់បានស្ដាប់សេចក្ដីអធិស្ឋានរបស់ ទូលបង្គំ ដែលទូលបង្គំឥឡូវជាកូនរបស់ទ្រង់ ហើយនៅថ្ងៃណាមួយ ទូលបង្គំនឹងនៅជាមួយនឹងទ្រង់ នៅស្ថានសួគ៌។ អាម៉ែន!"



លោកបណ្ឌិត (សាស្ត្រាចារ្យ) វែននើរ គីត

Original Title: Wie komme ich in den Himmel?
Author‘s home page: www.wernergitt.com

Publisher: Bruderhand Medien
Am Hofe 2, 29342 Wienhausen; Germany
Tel.: +49 (0) 51 49 98 91-0, Fax: -19
E-Mail: info@bruderhand.de; Homepage: bruderhand.de

Nr. 120-63 – Kambodschanisch/Cambodian – 2nd edition 2022

# តើខ្ញុំអាច ទៅស្ថានសួគ៌ ដោយរបៀបណា?

រៀបរៀងដោយ
លោកបណ្ឌិត វែននើរ គីត

# តើខ្ញុំអាចទៅស្ថានសួគ៌ដោយរបៀបណា?

មានមនុស្សជាច្រើនព្យាយាមមិនបានគិតពីភាពអស់កល្បជានិច្ច ។ សូម្បីតែអស់អ្នកដែលបានគិតអំពី សេចក្ដីស្លាប់ គឺពួកគេព្យាយាមមិនគិតអំពីតើនឹងមានអ្វីកើតឡើងបន្ទាប់ពីសេចក្ដីស្លាប់ឡើយ។ កាលដែល ខ្ញុំនៅពីក្មេង មានតួឯកជាស្ត្រីរបស់អាមេរិចម្នាក់ឈ្មោះថា ទ្រូ បារីម័រ (Drew Barrymore) (នាង បានកើតនៅក្នុងឆ្នាំ ១៩៧៥) បានដើរជាតួឯកនៅក្នុងភាពយន្តមួយឈ្មោះថា "E.T." ។ នៅពេល ដែលនាងមានអាយុ២៨ឆ្នាំ នាងបាននិយាយថា៖ "បើខ្ញុំត្រូវស្លាប់នៅចំពោះមុខឆ្មាររបស់ខ្ញុំ នោះ ខ្ញុំអាចឲ្យផេះនៃសពរបស់ខ្ញុំឲ្យវាស៊ីបាន ។ បន្ទាប់មកទៀតគឺខ្ញុំអាចរស់នៅក្នុងខ្លួនឆ្មាររបស់ ខ្ញុំ"។ តើនេះវាមិនមែនជាការគិតខ្លី និងល្ងង់ខ្លៅទេឬអី?

ខណៈពេលដែលព្រះយេស៊ូវនៅមានព្រះជន្មនៅឡើយ មានមនុស្សជាច្រើនបានមកឯទ្រង់។ បញ្ហា របស់ពួកគេជាទូទៅគឺជាប់ទាក់ទងជាមួយនឹងពេលបច្ចុប្បន្ន។

- មានអ្នកកើតឃ្លង់ចំនួន១០នាក់ចង់ជាសះស្បើយ (លូកា ១៧៖១៣)
- មនុស្សខ្វះចង់មើលឃើញវិញ (ម៉ាកុស ៩៖២៧)
- មានមនុស្សម្នាក់ទៀតចង់ឲ្យព្រះយេស៊ូវជួយដោះស្រាយទៅលើជម្លោះកេរ្តិ៍មរត៌ក (លូកា ១២៖ ១៣-១៤)
- ពួកផារ៉ាស៊ីបានសួរសំនួរដែលពេញដោយល្បិចកល្បទៅព្រះយេស៊ូវថាតើពួកគេគួរតែ បង់ពន្ធទៅសេសាដែរឬទេ? (ម៉ាថាយ ២២៖២៧)។

មានមនុស្សតិចតួចណាស់បានមកឯព្រះយេស៊ូវដើម្បីស្ដាប់ថាតើពួកគេត្រូវធ្វើដូចម្ដេចដើម្បីទៅនគរ ស្ថានសួគ៌។ មាននាម៉ឺនម្នាក់ទូលសួរទ្រង់ថា *"ឱលោកគ្រូល្អអើយ! តើត្រូវអោយខ្ញុំធ្វើដូចម្ដេច អោយបានជីវិតរស់អស់កល្បជានិច្ច?"* (លូកា ១៨៖១៨)។ ព្រះយេស៊ូវមានបន្ទូលប្រាប់ដល់គាត់ឲ្យ លក់ទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ ហើយដើរតាមទ្រង់។ ពីព្រោះតែការដែលគាត់ជាអ្នកមាន គាត់ មិនបានស្ដាប់តាមបង្គាប់របស់ព្រះយេស៊ូវឡើយ ហេតុនេះគាត់មិនអាចទៅស្ថានសួគ៌បានឡើយ។ តែម្យ៉ាងវិញទៀត គឺមានមនុស្សជាច្រើនដែលមិនបានស្វែងរកស្ថានសួគ៌ ប៉ុន្តែនៅពេលដែលគេបានស្ដាប់ឮអំពីស្ថានសួគ៌ នៅពេលដែលគេបានជួបជាមួយនឹងព្រះយេស៊ូវ ពួកគេក៏ចាប់យកឱកាសនេះ ភ្លាមៗ។ លោកសាខេគឺចង់ឃើញព្រះយេស៊ូវ តែគាត់បានទទួលជាងអ្វីដែលគាត់បានរំពឹងទុកទៅទៀត ។ នៅពេលដែលព្រះយេស៊ូវយាងទៅផ្ទះរបស់គាត់ ខណៈពេលដែលពួកគេបានផឹកតែជាមួយនឹងគ្នា នោះគាត់បានរកឃើញនគរស្ថានសួគ៌។ *"ថ្ងៃនេះសេចក្ដីសង្គ្រោះបានមកដល់ផ្ទះនេះហើយ"* (លូកា ១៩៖១៩)។

## តើខ្ញុំអាចស្វែងរកស្ថានសួគ៌ដោយរបៀបណា?

តាមរយៈអ្វីដែលយើងបានឃើញខាងលើ យើងអាចនិយាយបានថា៖

- នគរស្ថានសួគ៌គឺអាចស្វែងរកឃើញនៅពេលវេលាមួយដែលជាក់ច្បាស់។ វាជាល្អណាស់ សម្រាប់បងប្អូនជាទីស្រលាញ់ដែលបានអានដើម្បីស្គាល់អំពីនគរស្ថានសួគ៌ ពីព្រោះវាមាន ន័យសំខាន់សម្រាប់អ្នកពីព្រោះអ្នកអាចចាប់យកជីវិតអស់កល្បជានិច្ចបាននៅថ្ងៃនេះបាន។
- នគរស្ថានសួគ៌មិនអាចសម្រេចបានតាមរយៈកិច្ចការល្អបានឡើយ។
- មនុស្សម្នាក់អាចសម្រេចបាននគរស្ថានសួគ៌ ដោយមិនចាំបាច់មានការរៀបចំជាងមុនឡើយ។

រាល់គំនិតរបស់យើងទាំងអស់ដែលយល់ថា តើយើងទៅនគរស្ថានសួគ៌ដោយរបៀបណា? គឺខុសទាំងអស់ ប្រសិនបើគំនិតទាំងនោះមិនពឹងផ្អែកទៅលើអ្វីដែលព្រះជាម្ចាស់បានព្រះបន្ទូលនោះទេ។ មានអ្នក ចម្រៀងម្នាក់បានច្រៀងចំរៀងមួយបទអំពីអ្នកកំប្លែងម្នាក់ដែលបានចូលនិវត្តន៍ពីការសម្ដែងរបស់ គាត់ បន្ទាប់ពីបានសម្ដែងជាច្រើនឆ្នាំមក។ នៅក្នុងចម្រៀងនោះគឺ "គាត់ប្រាកដជាទៅស្ថានសួគ៌ ពីព្រោះគាត់បានធ្វើឲ្យមនុស្សជាច្រើនបានរីករាយ"។ មានស្ត្រីអ្នកមានម្នាក់បានសង់ផ្ទះមួយសម្រាប់ អ្នកក្រ ដែលអាចមានស្ត្រីក្រីក្រចំនួន២០រស់នៅបាន ហើយគាត់មិនតម្រូវឲ្យបង់ថ្លៃអ្វីនោះទេ។ គឺមានលក្ខខណ្ឌតែមួយគត់៖ ស្ត្រីទាំងនោះត្រូវតែសន្យាថា ពួកគេនឹងអធិស្ឋានសម្រាប់សេចក្ដី សង្គ្រោះដល់ស្ត្រីដែលជាអ្នកមាននោះរយៈពេលមួយម៉ោងជារៀងរាល់ថ្ងៃ។

ព្រះយេស៊ូវមានបន្ទូលអំពីពាក្យប្រៀបធៀបដើម្បីជួយពន្យល់អំពីសេចក្ដីនេះ។ នៅក្នុងដំណឹងល្អតាម រយៈលោកលូកាជំពូកទី១៤៖១៦៖ ទ្រង់បានមានបន្ទូលអំពីបុរសម្នាក់ (នៅក្នុងពាក្យប្រៀបធៀប នោះគឺជាព្រះជាម្ចាស់) ដែលទ្រង់បានរៀបចំពិធីជប់លៀងមួយដ៏ធំ។ គាត់បានចាត់ឲ្យអ្នកបំរើទៅ អញ្ជើញមនុស្សឲ្យមកចូលរួមក្នុងពិធីនេះ ប៉ុន្តែរាល់ការឆ្លើយតបរបស់ពួកគេបានធ្វើឲ្យគាត់បានការខក ចិត្ត៖ *"តែគេចាប់តាំងដោះសារដូចគ្នាទាំងអស់ អ្នកមុននិយាយថា ខ្ញុំបានទិញចំការ..." "ម្នាក់ទៀតថាខ្ញុំបានទិញគោ៥នឹម ខ្ញុំត្រូវទៅលវាមើល..." "ម្នាក់ទៀតក៏ថាខ្ញុំទើបនឹងការប្រពន្ធ ហើយ ដោយហេតុ នោះបានជាខ្ញុំទៅមិនបាន"*។ ព្រះយេស៊ូវបានបញ្ចប់ការនិយាយជាពាក្យប្រៀប ធៀបនេះដោយពាក្យថា៖ *"ដ្បិតអញប្រាប់ថា ឯពួកមនុស្សទាំងប៉ុន្មាន ដែលអញបានអញ្ជើញមកមុននោះ អញលែងអោយអ្នក ណា១ភ្លក់ម្ហូបរបស់អញហើយ"* (លូកា ១៤៖២៤) ។

នៅក្នុងពាក្យប្រៀបធៀបនេះ វាបានបង្ហាញយ៉ាងច្បាស់ថា យើងមិនអាចឈ្នះ ឬចាញ់នគរស្ថានសួគ៌ នោះឡើយ។ កិច្ចការដែលសំខាន់នោះគឺថា តើអ្នកនឹងទទួលការអញ្ជើញ ឬបដិសេធចំពោះការ អញ្ជើញ។ តើវាមិនមែនជាការងាយស្រួលជាងទេឬអី? ប្រសិនបើមនុស្សម្នាក់មិនអាចទៅនគរស្ថាន សួគ៌ នៅពេលដែលពេលវេលាបានមកដល់ នោះមិនមែនមកពីពួកគេមិនស្គាល់ផ្លូវនោះទេ ប៉ុន្តែគឺមក ពីពួកគេមិនទទួលការអញ្ជើញ។

ចំពោះមនុស្ស៣នាក់ដែលស្ថិតនៅក្នុងពាក្យប្រៀបធៀបរបស់ព្រះយេស៊ូវគឺមិនមែនជាគំរូល្អសម្រាប់ យើងនោះទេ។ គ្មាននរណាម្នាក់ក្នុងចំណោមពួកគេបានទទួលការអញ្ជើញទៅក្នុងពិធីជប់លៀងនោះឡើយ។ ជាលទ្ធផល តើពិធីជប់លៀងត្រូវបានលុបចោលឬ? ទេ! ពិធីជប់លៀងមិនត្រូវបានបញ្ឈប់ នោះឡើយ ដោយព្រោះតែភ្ញៀវដែលបានអញ្ជើញមកបដិសេធមកចូលរួម នោះចៅហ្វាយក៏បាន អញ្ជើញមនុស្សទាំងអស់នៅក្នុងលោកីយនេះមកចូលរួម។ ទាំងនេះមិនមែនជាការអញ្ជើញជាមួយនឹង សំបុត្រពណ៌មាសនោះទេនៅពេលនេះ វាជាការអញ្ជើញធម្មតាមួយ៖ "ចូលមក!"។ ហើយមនុស្ស ដែលទទួលការអញ្ជើញត្រូវបានផ្ដល់កន្លែងសម្រាប់អង្គុយ។ តើមានអ្វីកើតឡើង? មានហ្វូងមនុស្ស បានចូលមក។ បន្ទាប់មកចៅហ្វាយបានមើលទៅគឺនៅមានកន្លែងទំនេរ។ រួចចៅហ្វាយប្រាប់ថា "ចូរចេញទៅតាមផ្លូវច្រកល្ហក តាមរបង ហើយបង្ខំគេអោយចូលមក ដើម្បីអោយផ្ទះ អញបាន ពេញ"។

រហូតមកដល់ចំណុចនេះ ខ្ញុំចង់ពិនិត្យមើល ថាតើពាក្យប្រៀបធៀបនេះមានអ្វីទាក់ទងជាមួយនឹងពួក យើងសម័យបច្ចុប្បន្ន។ គឺនៅមានបន្ទប់នៅនគរស្ថានសួគ៌ ហើយព្រះជាម្ចាស់មានបន្ទូលប្រាប់ដល់អ្នកថា៖ "ចូរមក ហើយយកន្លែងរបស់អ្នកនៅស្ថានសួគ៌! ចូរធ្វើការសម្រេចចិត្តមួយដែលត្រឹមត្រូវ ហើយរក្សាកន្លែងមួយសម្រាប់អ្នកដ៏អស់កល្បជានិច្ច! ចូរសម្រេចចិត្តនៅថ្ងៃនេះ!"។

ស្ថានសួគ៌គឺពេញដោយការអស្ចារ្យ ។ ហេតុនេះបានជាព្រះយេស៊ូវបានប្រៀបធៀបស្ថានសួគ៌ទៅនឹងពិ ធីជប់លៀងមួយ។ នៅក្នុងបទគម្ពីរ ១កូរិនថូស ២៖៩ ចែងមកថា៖ *"សេចក្ដីដែលភ្នែកមិនដែលឃើញ ត្រចៀកមិន ដែលឮ ហើយចិត្តនឹកមិនដែលដល់ គឺសេចក្ដីនោះឯង ដែលព្រះបានរៀបចំទុក សំរាប់ពួកអ្នក ដែលស្រឡាញ់ទ្រង់"* ។ គឺគ្មានកន្លែងណាមួយនៅលើផែនដីនេះ ដែលដូចជាអ្វីដែលនៅស្ថានសួគ៌នោះឡើយ។ ស្ថានសួគ៌គឺពិតជាអស្ចារ្យណាស់! ដូច្នេះយើងមិនអាចបាត់បង់ស្ថានសួគ៌ បានឡើយ។ ស្ថានសួគ៌ជាកន្លែងដែលវិសេសដែលមិនអាចជឿបាន។ ព្រះយេស៊ូវ ជាព្រះរាជបុត្រា របស់ព្រះជាម្ចាស់ គឺជាព្រះអម្ចាស់ដែលបានបើកផ្លូវទៅនគរស្ថានសួគ៌សម្រាប់យើង!។ ទ្រង់គឺជាអ្នកដែលបានធ្វើឲ្យមានភាពងាយស្រួលសម្រាប់ពួកយើងដើម្បីទៅនគរស្ថានសួគ៌។ គឺមានតែកិច្ចការចាំ បាច់សម្រាប់យើងតែមួយគត់ ដើម្បីសម្រេចចិត្តគឺយើងទៅស្ថានសួគ៌ ក៏មិនទៅស្ថានសួគ៌។ គឺមានតែ មនុស្សដែលមើលមិនឆ្ងាយដូចជាមនុស្សមួយចំនួននៅក្នុងពាក្យប្រៀបធៀបប៉ុណ្ណោះដែលនឹងបដិសេធ ចំពោះការអញ្ជើញរបស់ព្រះជាម្ចាស់។



## សេចក្ដីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូវ

នៅក្នុងបទគម្ពីរកិច្ចការ ២៖២១ យើងអាននូវខគម្ពីរមួយយ៉ាងសំខាន់គឺ៖ *"នោះអស់អ្នកណាដែល អំពាវនាវដល់ ព្រះនាមព្រះអម្ចាស់គេនឹងបានសង្គ្រោះ"* ។ នេះគឺជាបទគម្ពីរជាមូលដ្ឋានគ្រឹះនៅក្នុងព្រះ គម្ពីរសញ្ញាថ្មី។

នៅពេលដែលសាវ័កប៉ូលស្ថិតនៅក្នុងគុកនៅក្រុងភីលីព គាត់បានធ្វើការសង្ខេបនៅក្នុងការសន្ទនា របស់គាត់ជាមួយនឹងអ្នកយាមគុកដោយនិយាយថា៖ "ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទៅនោះនឹងបានសង្គ្រោះ ហើយព្រមទាំងពួកគ្រួសារលោកផង ?" (កិច្ចការ ១៦៖៣១) ។ ការចែកចាយរបស់ គាត់ខ្លី ប៉ុន្តែជាមួយនឹងគ្នានោះវាពិតនិងអាចផ្លាស់ប្រែជីវិតបាន។ អ្នកយាមគុកបានប្រែចិត្តនៅក្នុងយប់នោះ។

តើព្រះយេស៊ូវសង្គ្រោះយើងចេញពីអ្វី?នេះជាសំនួរមួយដែលសំខាន់ដើម្បីនឹងសួរ ។ ទ្រង់បាន សង្គ្រោះ យើងចេញពីផ្លូវដែលនាំយើងទៅរកសេចក្ដីមហន្តរាយអស់កល្បជានិច្ច ដែលជាស្ថាននរក។

ព្រះគម្ពីរបានប្រាប់ដល់យើងថា មនុស្សទាំងឡាយនឹងស្ថិតនៅក្នុងនគរស្ថានសួគ៌ ឬក្នុងស្ថាននរកនៅ ពេលដែលគេស្លាប់ទៅ។ មានកន្លែងមួយក្នុងចំណោមកន្លែងទាំងពីរមានភាពអស្ចារ្យ ហើយកន្លែងមួយទៀតគឺគួរឲ្យភ័យរន្ធត់។ ជាមួយនឹងគ្នាគឺគ្មានការដែលអាចផ្លាស់ប្ដូរបានឡើយ។ រយៈចំនួន៥នាទី បន្ទាប់ពីពួកគេបានស្លាប់ គឺវាគ្មានឱកាសទៀតទេចំពោះមនុស្សដែលជឿថាសេចក្ដីស្លាប់ជាទីបញ្ចប់នៃ អ្វីៗទាំងអស់នោះ។ ជីវិតរបស់អ្នកនឹងត្រូវបានជំនុំជំម្រះតាមរយៈចំណងទាក់ទងរបស់អ្នកជាមួយនឹងព្រះយេស៊ូវគ្រីស្ទ។ នោះហើយគឺជាការសម្រេចចិត្ត ដែលអ្នកនឹងចំណាយភាពអស់កល្បរបស់អ្នក។

នៅពេលដែលខ្ញុំស្ថិតនៅប្រទេសប៉ូឡូញ ក្នុងដំណើរនៃការចែងចាយព្រះបន្ទូល ពួកយើងបានទៅធ្វើ ទស្សនៈកិច្ចនៅក្នុងអតីតជំរុំជនភៀសខ្លួន អូសស្វីស (Auschwitz)។ មានការកើតឡើងគួរឲ្យភ័យខ្លាច នៅទីនោះនៅក្នុង រេជទី៣ (Third Reich) (ក្នុងកំឡុងពេលសង្គ្រាមលោកលើកទី២)។ នៅក្នុងរវាងឆ្នាំ ១៩៤២ និង ១៩៤៤ គឺមានមនុស្សចំនួន ១.៦លាននាក់ត្រូវបានសម្លាប់ ភាគច្រើនគឺសាសន៍យូដា (ជនជាតិជ្វីប) ហើយខ្លួនប្រាណរបស់ពួកគេត្រូវបានដុតចោល។ តាមពិតទីនោះ ជាទូទៅត្រូវបានគេហៅ ថាជា "ស្ថាននរកនៃអូសស្វីស"។ ការពិពណ៌នានេះបានឆ្លងកាត់គំនិតរបស់ខ្ញុំ